# បទពិសោធន៍កសិករដាំដំណាំត្រប់

ដោយ : មន្ទីរកសិកម្ម ខេត្តស្វាយរៀង

១/ប្រវត្តិ :

-លោកពូ ឃួន .នួន អាយុ ៦០ ឆ្នាំ ជាកសិករគំរូ បច្ចុប្បន្នរស់នៅ ភូមិស្វាយក្អែ ឃុំតាសួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ។

-រូបលោកពូផ្ទាល់ រួមជាមួយកសិករ ដាំដំណាំបន្លែមានសមាជិក១២ គ្រួសារ ចងក្រងជាសមាគមដាំបន្លែប្រើប្រាស់ជីធម្មជាតិ ជីកំប៉ុស្ត និងកាកសំណល់ផ្ទះបាយសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ និងលក់លើទីផ្សារ ។

-នៅថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ ២០០៩ លោក **ថាច់ រតនា** ប្រធានមន្ទីរកសិកម្ម ខេត្តស្វាយរៀង បានប្រគល់ម៉ាស៊ីនបូមទឹក១គ្រឿង គ្រាប់ពូជដំណាំ៥មុខដែលមាន គ្រាប់ស្ពៃមើម ស្ពៃផ្កា ត្រប់ សណ្តែកកួរ និងត្រគួន ឯកសារបច្ចេកទេសកសិកម្មក្នុង១គ្រួសារ ៨ ច្បាប់ x ចំនួន១២ គ្រួសារ= ៩៦ ជូនដល់សមាជិកសម្រាប់ប្រើប្រាស់ ជាកម្មសិទ្ធិរបស់រួម ក្នុងសមាគមដាំដំណាំបន្លែ គិត ជាទឹកប្រាក់ជាង ២០០ ដុល្លារ ។

-ដំណើរការប្រគល់ សម្ភារកសិកម្មនេះមានការចូលរួមពីក្រុមប្រឹក្សាឃុំតាសួសលោក ហែម វ៉ែន មេឃុំផងដែរ ។

-នៅក្នុងឱកាសនោះដែរ លោកប្រធានមន្ទីរកសិកម្មខេត្ត ជម្រាបជូនកសិករទាំងអស់ពីគោលបំណងរៀបចំសមាគមដាំដំណាំបន្លែសម្រាប់ដោះស្រាយជីវភាពគ្រួសារ ផង និង ផ្គត់ផ្គង់ប្រគួតប្រជែងរកទីផ្សារក្នុងស្រុក ឬ ក្រៅស្រុក តាមរយៈប្រព័ន្ធចុះកិច្ចសន្យា រវាងអ្នកផលិត និង អ្នកទិញ នូវផលិតផលមិនប្រើប្រាស់ថ្នាំពុល ជីគីមី ។

២/ស្ថានភាពគ្រួសាររបស់លោកពូ ឃួន.នួន

-លោកពូ ឃួន.នួន បានបញ្ជាក់ប្រាប់ទៀតថា ៖- បច្ចុប្បន្ន គាត់មានសមាជិកគ្រួសារសរុប ៧ នាក់



ការផ្តល់ម៉ាស៊ីនបូមទឹកជូនទ្រជាកសិករ

ស្រី ៤ នាក់ នៅក្នុងបន្ទុក មានផ្ទៃដីបង្កបង្កើនផលស្រូវ ២ ហិកតា ផ្ទៃដីដាំដំណាំ និងសង់ផ្ទះ ០,២០ អាមានគោ ៥ ក្បាល មាន់ ធំ-តូច ៣០ ក្បាល ទា ធំ-តូច ២២ក្បាល និងស្រះចិញ្ចឹមត្រី១កន្លែង ក្រៅពីធ្វើស្រែរដូវវស្សា គ្រួសារលោកពូព្យាយាមខិតខំដាំដំណាំ នៅក្នុងភូមិរបស់គាត់ មិនឲ្យសល់ដីទំនេរឡើយ រួមមានដំណាំឃ្លោក ត្រឡាច ត្រសក់ សណ្តែកកួរ ល្ពៅ ដីវ៉ាន់សុយ ដំឡូងឈើ ដំណាំទាំងអស់នោះ លោក ពូ ឃួន .នួន បានបញ្ជាក់ច្បាស់ទៀតថា ៖-មានតែដំណាំត្រប់ទេ ដែលកន្លងមកគាត់ចាប់អារម្មណ៍ ព្រោះវាបានផ្តល់ផលខ្ពស់ជាងគេ និងមានរយៈពេលផ្តល់ផលយូរទៀតផង ។

លោកពូ **ឃួន នួន** ជាកសិករគំរូបានមានប្រសាសន៍បន្តទៀតថា ៖- គាត់មកតាំងលំនៅដ្ឋានលើភូមិនេះពីឆ្នាំ ១៩៨០ រហូតមកបានអនុវត្តន៍ ការងារការចិញ្ចឹមសត្វ ការធ្វើស្រែ និង ការដាំដុះដំណាំ កសិកម្មគឺធ្វើតាមទំលាប់ បែបពីបុរាណ ពុំធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលអ្វីទេ ការចិញ្ចឹមសត្វ ពុំដែលស្គាល់ចាក់វ៉ាក់សាំងទេ រីឯជីវភាពគ្រួសារជួបប្រទះនូវការខ្វះខាតស្បៀងជារៀងរាល់ឆ្នាំ ។

※ ទើបតែនៅឆ្នាំ ២០០៥ ភូមិស្វាយក្អែ ឃុំ

តាសួស ស្រុកស្វាយជ្រំ ត្រូវបានមន្ទីរកសិកម្មខេត្ត ជ្រើសរើសឲ្យចូលក្នុងកម្មវិធីគម្រោង កាត់បន្ថយភាពក្រីក្រនៅជនបទ ( RPRP ) កសិករក្នុងភូមិ និងគ្រួសាររបស់គាត់ត្រូវបានជ្រើសរើសជាក្រុម ( SRI ) បានឆ្លងកាត់វគ្គបណ្តុះបណ្តាល បច្ចេកទេសកសិកម្មពីភ្នាក់ងារមន្ទីរកសិកម្មខេត្ត ក្នុងការធ្វើបង្ហាញស្រូវ បន្លែ ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី រៀនផង និងអនុវត្តន៍ជាក់ស្តែងផង គ្រួសារគាត់ខិតខំព្យាយាមទទួលបានជោគជ័យជាកសិករគំរូ ១រូប ក្នុងភូមិ ហើយបានផ្តល់បទពិសោធន៍ជាក់ស្តែងនោះជូនប្រតិភូមកធ្វើទស្សនៈកិច្ចសិក្សាចំនួន ៣ លើកវគ្គមានចូលរួម៦៥នាក់ស្រី២៨នាក់ ។

ក្រោយពីបានចូលរួមរៀនសូត្រវគ្គបណ្តុះបណ្តាល វែង ឬ ខ្លី និងបទពិសោធន៍ដែលបានផ្លាស់ប្តូរពីគ្នាទៅវិញទៅមកនេះធ្វើឲ្យគ្រួសាររបស់ខ្ញុំកាន់តែចាប់អារម្មណ៍ និងធ្វើឲ្យជីវភាពគ្រួសារកាន់តែប្រសើរឡើងៗជាលំដាប់ មានប្រាក់ចំណូលជាប្រចាំ រៀងរាល់ថ្ងៃ ចំណូលដែលបានទិន្នផលច្រើនជាងគេ គឺដំណាំត្រប់ ។

៣/របៀបដាំត្រប់ :

❋ រៀបចំដីបណ្តុះកូន :

-ធ្វើថ្នាលដីឲ្យរាបស្មើ ហាលដីឲ្យស្ងួតនិងធ្វើឲ្យដីម៉ត់ល្អ ។

-យកជីលាមកសត្វ និងផេះមកច្របល់ចូលគ្នាឲ្យបានសព្វល្អ ។

-យកគ្រាប់ទៅហាលថ្ងៃ២-៣ម៉ោង រួចយកគ្រាប់មកខ្ចប់ត្រាំទឹករយៈពេលពី៣-៤ម៉ោង លើកកញ្ចប់នោះឡើងពីទឹក យកទៅកប់ក្នុងដីដែលមានសំណើមសើមៗ រយៈពេលពី៣-៤ ថ្ងៃ ឃើញគ្រាប់ត្រប់នោះបែកមាត់ចាបចេញ សៗ ទើបយើងយកទៅព្រោះក្នុងថ្នាលដែលបានរៀបចំរួច ។

-បន្ទាប់មកទៀតយកកញ្ច្រែង និងជីលាមកសត្វ ផេះ រែងដាក់ពីលើថ្នាល ដែលបានព្រោះគ្រាប់រួច ជៀសវាងកុំឲ្យស្រមោចមករោមស៊ី ឬ ជញ្ជូនយកចេញពីថ្នាល ។

-រយៈពេលពី ១៥-២០ ថ្ងៃ ទើបដកយកទៅស្ទូងតាមរងបាន

❋ របៀបធ្វើរងដាំ :



-ទទឹងរង ១ ម៉ែត្រ បណ្តោយរង តាមស្ថានភាព និងភូមិសាស្ត្រដីដែលមាន លើករងកំពស់ប្រហែលពី ០.២ ទៅ ០.៥ ម៉ែត្រ ការពារនូវរដូវវស្សាទឹកជន និងឃ្លាតគ្នាពីរង១ ទៅ រងមួយទៀត ០.៥ ម៉ែត្រងាយស្រួលក្នុងការដើរថែទាំ ដាក់ជី ឬ ស្រោចទឹកជាដើម ។

-ការដាំត្រប់ គឺដាំនៅពេលល្ងាចមុនគាស់កូនទៅដាំ ត្រូវស្រោចទឹកសិន និងគាស់ថ្នមៗ ។

-រយៈពេលពី ១៥-២០ ថ្ងៃ ទើបដកយកទៅដាំនៅតាមរង

-ជីករណ្តៅតាមរងជម្រៅពី ០.៧០ស.ម ទៅ ១ តឹក ដាក់ជីលាមកសត្វ និងសំរាមពុកៗទ្រាប់បាតទើបយកកូនត្រប់ទៅកប់នៅតាមរណ្តៅ ។

-ការដាំត្រប់ ដាំឃ្លាតពីគ្នាពី ០.៤ ម៉ែត្រ ទៅ០.៥ ម៉ែត្រ នៅពេលត្រប់ចាប់ផ្តើមចេញផ្កាត្រូវដាក់ជីលាមកសត្វតាមរងបំប៉នរួចពូនលប់គល់ត្រប់តែម្តង ។

- រយៈពេលទទួលផលពី ៧៥ ទៅ ៩០ ថ្ងៃ

- ការថែទាំ ត្រូវបញ្ចូលទឹកឲ្យសើមៗតាមរង និងរែកមើលតាមបណ្តូលត្រប់រាល់ថ្ងៃការពារដង្កូវស៊ី ។

❋ លទ្ធផលទទួលបាន :

- ត្រប់ដាំបាន ៤៥ រង x ៣០ គុម្ព = ១.៣៥០ គុម្ព ១ គុម្ព x ៥ គ.ក្រ x ១.៣៥០ គុម្ព = ៦.៧៥០ គ.ក្រ

- តម្លៃ ១ គ.ក្រ ស្មើ ១.៥០០៛ x ៦.៧៥០ គ.ក្រ =១០.១២៥.០០០ អតិថិជន មកទិញដល់ផ្ទះ ។

-បើយកទៅលក់ទីផ្សារដោយខ្លួនឯងផ្ទាល់ក្នុង ១ គ.ក្រ ២.០០០ ទៅ ២.២០០ ៛ ប៉ុន្តែ សព្វនេះ









ច្រើនគេមកយកដល់ទីកន្លែងដាំ គឺបេះលក់ដុំឲ្យម៉ូយតែម្ដង។

៙ ការចំណាយក្នុងការដាំត្រប់ ( វដ្ដជីវិត ) គឺចំណាយអស់តិចតួចទេ ៖-

-ទិញប្រេងបូមទឹកស្រោច ទិញសម្ភារសម្រាប់ប្រើប្រាស់ ដូចជាចប ធុងស្រោច បង្គី រនាស់និងកជ្រួយដីពាងសម្រាប់ធ្វើជីកំប៉ុស្ដ និងសំណាញ់សម្រាប់រាំងកន្លែងធ្វើថ្នាលបណ្ដុះកូនត្រប់ ចំណាយសរុប=៣៥០.០០០៛

-រីឯការថែទាំ និង ការប្រមូលផលវិញ គឺប្រើប្រាស់កំលាំងគ្រួសារខ្លួនឯងតែម្ដង ។

-ចំណេញពីការដាំត្រប់ =១០.១២៥.០០០៛

- ចំណាយ៣៥០.០០០៛

- ចំណេញ ៩.៧៧៥.០០០៛ នៅរដូវត្រប់

រាល់ថ្ងៃកសិករក្នុងភូមិមកទំនាក់ទំនងជាមួយគាត់ដើម្បីស្វែងយកបទពិសោធន៍ពីគ្នាទៅវិញទៅមក។

ដោយសារការជួយឧបត្ថម្ភគាំទ្រពីមន្ទីរកសិកម្មខេត្ត និងកម្មវិធី RPRP ទាំងផ្នែកស្មារតី បច្ចេកទេសគ្រួសារមានជីវភាពធូរធារជាបណ្ដើរៗ មានប្រាក់ចំណូលរាល់ថ្ងៃ ។

សូមឲ្យកសិករដទៃទៀតអនុវត្តតាមរបៀបនេះទើបជីវភាពធូរធារ និងកាត់បន្ថយបាននូវការធ្វើចំណាកស្រុក ។